

# ព្រះរាជជីវប្រវត្តិនៃសម្ដេចព្រះមហា សុមេធាធិបតី ជួន ណាត ព្រះសង្ឃ
# រាជថ្នាក់ទី១ នៃគណៈមហានិកាយ

កំណត់ត្រាសិលា

http://www.seylanote.wordpress.com

*__រៀបរៀងដោយ៖__*

*ព្រះមុនីកោសល សូរ ហាយ តាមឯកសារខ្វះរបស់ព្រះឃោសធម្ម ប៉ុណ្យ សុម្កោជ និងលោកទ្រិញ វ៉ាញ ១៩៧០ ( ចម្លងចេញពីទស្សនាវដ្ដី អក្សរសាស្ត្រ មនុស្សសាស្ត្រ របស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ) លេខពិសេស ខែធ្នូ ឆ្នាំ១៩៩៨ និងលេខពិសេស ខែមករា កុម្ភៈ មីនា ឆ្នាំ១៩៩៩។*

*__អារម្ភកថា :__*

*ខ្ញុំព្រះករុណាអាត្មាភាព ជាសមាជិកនៃ គណៈកម្មការឃោសនា ដោយមានលោកទ្រិញ វ៉ាញ ជាប្រធាននៃគណៈកម្មការ អស់លោកជាសមាជិកគណៈកម្មការទាំងអស់មានលោក លាង ហាប់អាន ជាដើម បានផ្ទុកផ្ដាក់នូវការស្រាវជ្រាវរៀបរៀងព្រះរាជជីវប្រវត្តិ នៃសម្ដេចព្រះសង្ឃរាជមកលើខ្ញុំព្រះករុណាអាត្មាភាព ដូចមានលិខិតលេខ ៨២៤ ព.ប ចុះថ្ងៃ ទី៧ ខែតុលា ឆ្នាំ ១៩៦៩ ជាលិខិតលោក លាង ហាប់អាន នាយកវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ដែលតម្រូវមកលើខ្លួនខ្ញុំព្រះករុណាអត្មាភាពឲ្យស្រាវជ្រាវ រៀបរៀងព្រះរាជជីវប្រវត្តិនៃសម្ដេចព្រះសង្ឃរាជជាអម្ចាស់។*

*ខ្ញុំព្រះករុណាអត្មាភាព សូមទទួលការនេះដោយគោរព តាមសមានឆន្ទៈនៃគណៈកម្មការ។ ព្រះរាជជីវប្រវត្តិនៃសម្ដេចព្រះសង្ឃរាជនេះ ខ្ញុំព្រះករុណាអត្មាភាពសូមចែកជាបរិច្ឆេទ១២ ដើម្បីឲ្យងាយមើលចំណាំក្នុងបរិច្ឆេទមួយៗ តាមរយៈកាលនៃព្រះជីវភាព ព្រះវិរយភាព និងព្រះករណីយកិច្ចនៃ សម្ដេចព្រះសង្ឃរាជ ព្រមទាំងឲ្យងាយស្រួលក្នុងការរៀបរៀងវែកញែកសេចក្ដី ដូចតទៅនេះ៖*

*បរិច្ឆេទ១២យ៉ាង*

*១. ជាតិបរិច្ឆេទ៖ កំណត់អំពីជាតិ*
*២. កុមារបរិច្ឆេទ៖ កំណត់អំពីភាពនៅជាកុមារ*
*៣. បព្វជ្ជាបរិច្ឆេទ៖ កំណត់អំពីបព្វជ្ជា*
*៤. ឧបសម្បទានបរិច្ឆេទ៖ កំណត់អំពីឧបសម្បទា*
*៥. បរិយត្តិបរិច្ឆេទ៖ កំណត់អំពីការសិក្សា*
*៦. បេសកកម្មបរិច្ឆេទ៖ កំណត់អំពីការទទួលបម្រើកិច្ចការ*
*៧. ឋានន្តរបរិច្ឆេទ៖ កំណត់អំពីឋានន្តរ*
*៨. សមណសក្តិបរិច្ឆេទ៖ កំណត់អំពីសមណសក្តិ*
*៩. ឥស្សរិយបរិច្ឆេទ៖ កំណត់អំពីឥស្សរិយយស*
*១០. ពុទ្ធវុឌ្ឍិបរិច្ឆេទ៖ កំណត់អំពីការធ្វើសេចក្ដីចម្រើនក្នុងផ្លូវលោក និងផ្លូវព្រះពុទ្ធសាសនា*
*១១. ចរិតលក្ខណៈបរិច្ឆេទ៖ កំណត់អំពីលក្ខណៈនៃ ជីវិតប្រក្រតី*
*១២. ជីវិតាវសានបរិច្ឆេទ៖ កំណត់អំពីទីបំផុតនៃ ព្រះជន្មាយុ*

# អធិប្បាយចំពោះបរិច្ឆេទមួយៗ

## ១. ជាតិបរិច្ឆេទ (កំណត់អំពីជាតិ)

*សម្ដេចព្រះសង្ឃរាជ ទ្រង់ប្រសូតនៅថ្ងៃអង្គារ ១១រោច ខែផល្គុន ឆ្នាំរកា ឆស័ក ព.ស.២៤២៧ គឺថ្ងៃទី១១ ខែ មីនា គ.ស.១៨៨៣ នៅភូមិកំរៀង សង្កាត់រកាកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។ សម្ដេចមានព្រះជាតិក្នុងត្រកូលកសិករ ព្រះមាតានៃសម្ដេចនាម យក់ ព្រះបិតានាម ព្រហ្ម ជួន។ គ្រួសារនេះមានបុត្រតែពីរនាក់គឺ អង្គសម្ដេចព្រះសង្ឃរាជ និងលោកឧកញ៉ាសោភណ្ឌមន្ត្រី ជួន នុត ជាព្រះអនុជនៃ សម្ដេចព្រះសង្ឃរាជ។*

## ២. កុមារបរិច្ឆេទ (កំណត់អំពីភាពនៃកុមារ)

*សម្ដេចកាលឋិតនៅក្នុងកុមារភាព មានព្រះជន្មាយុរវាង១២ឆ្នាំ ព្រះមាតាបិតាបាននាំយកទៅផ្ញើផ្ដាក់ឲ្យរៀនសូត្រអក្សរសាស្ត្ររបស់ជាតិក្នុងសំណាក់លោកគ្រូសូត្រស្ដាំនាម កែ ម៉ម វត្តពោធិព្រឹក្ស ហៅវត្តពោល្បំ សង្កាត់រលាំងកែន ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល។*

## ៣. បុព្វជ្ជាបរិច្ឆេទ (កំណត់អំពីបព្វជ្ជា)

*លុះសម្ដេចមានព្រះជន្មាយុ១៤ឆ្នាំ បានបួសជាសាមណេរ ក្នុង ថ្ងៃ១៥កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៤៤១ គ.ស. ១៨៩៧ នៅបំពេញកិច្ចសិក្សានាវត្តពោធិព្រឹក្ស អស់រយៈកាលពីរឆ្នាំ ទើបចេញអំពីវត្តពោធិព្រឹក្សទៅរៀនសូត្រព្រះបរិយត្តិធម៌ឯវត្តឧណ្ណាលោម ក្រុងភ្នំពេញ ក្នុងសំណាក់ព្រះពុទ្ធគ្រូ ទេព សោ នាកុដិថៃវប្រែបកំពែងខាងជើងក្នុងកាលព.ស.២៤៤៣ គ.ស. ១៨៩៩។*

## ៤. ឧបសម្បទាបរិច្ឆេទ (កំណត់អំពីឧបសម្បទា)

*សម្ដេច លុះបានព្រះជន្មាយុគម្រប់២១ព្រះវស្សាបានទ្រង់និមន្តត្រឡប់ទៅសូម ឧបសម្បទាជាភិក្ខុ ក្នុងវត្តពោធិព្រឹក្សដែលជាវត្តដើមវិញ ដោយមានព្រះតេជព្រះគុណ ព្រះពុទ្ធឃោសាចារ្យ ម៉ា កេត សុវណ្ណប្បញ្ញោជាព្រះឧបជ្ឈាយ៍ កាលលោកនៅជាចៅអធិការវត្តពោធិព្រឹក្សមានព្រះតេជព្រះគុណ កែ ម៉ម មិស្សនាគោ ជាគ្រូសូត្រស្ដាំ និងព្រះតេជព្រះគុណ អ៊ឹម ខឹម តិក្ខប្បញ្ញោ ជាគ្រូសូត្រឆ្វេង សូត្របំពេញកិច្ចឧបសម្បទានៅថ្ងៃ១៤កើត ខែជេស្ឋ ឆ្នាំរោង ឆស័កព.ស.២៤៤៨ គ.ស.១៩០៤។ សម្ដេចទ្រង់ទទួលព្រះនាមបញ្ញត្តិថា ជោតញ្ញាណោ លុះទ្រង់បំពេញឧបសម្បទាជាភិក្ខុភាពរួចហើយ ទ្រង់ក៏និមន្តត្រឡប់មកគង់នៅវត្តឧណ្ណាលោម ទទួលការសិក្សាគន្ថធុរៈវិញទៀត។*

## ៥. បរិយត្តិបរិច្ឆេទ (កំណត់អំពីការសិក្សា)

*សម្ដេចព្រះសង្ឃរាជ មានសេចក្ដីព្យាយាមប្រកបដោយថាមពលដ៏ក្លៀវក្លាក្នុងការសិក្សា ទាំងផ្នែកភាសាបាលី ទាំងផ្នែកភាសាឯទៀតៗ មានភាសាបារាំងជាដើម។ ការសិក្សារបស់សម្ដេចព្រះសង្ឃរាជ មានជោគជ័យប្រសើរណាស់ ឃើញមានតែសម្ដេចសង្ឃរាជដែលរៀនចម្រើនលូតលាស់ មានល្បឿនឈ្នះលោកឯទៀតៗ។ សម្ដេចចាប់រៀនដំបូងមេសូត្រ ប្រែមូលកច្ចាយនៈ និងគម្ពីរធម្មបទអំពីព្រះពុទ្ធឃោសាចារ្យព្រះនាម ម៉ា កេត ដែលជាព្រះឧបជ្ឈាយ៍ នៃសម្ដេចព្រះសង្ឃរាជ។*

*សម្ដេចព្រះសង្ឃរាជ ដែលទ្រង់ចាប់រៀនវិជ្ជាណាមួយ មានវិជ្ជាបាលីជាដើម គឺរៀនដោយយកព្រះទ័យទុកដាក់ ខិតខំប្រឹងប្រែងឥតមានបន្ធូរបន្ថយក្នុងការសិក្សានោះឡើយ។*

*សម្ដេចទ្រង់ទទួលការសិក្សានោះគឺ សិក្សាដោយឆន្ទៈដ៏មានកម្លាំងមែនពិតៗ ពុំមែនសិក្សាវិជ្ជាណាមួយដោយលេងៗ ទេ។ វិជ្ជាខាងភាសាបាលី ភាសាសំស្ក្រឹត និងភាសាបារាំង សុទ្ធតែវិជ្ជាដែលប្រដាប់ដោយវេយ្យាករណ៍ហ្មត់ចត់ ជ្រាលជ្រៅលំបាករៀន លំបាកយល់ជាទីបំផុត ប៉ុន្តែសម្ដេចអាចរៀន អាចយល់ច្បាស់លាស់ ដោយឆាប់រហ័សគួរឲ្យកោតសរសើរពន់ពេកណាស់។*

*សម្ដេចទ្រង់ចេះដឹងយល់ធ្លុះធ្លាយចំពោះវេយ្យាករណ៍ គ្រប់ភាសា ដែលសម្ដេចបានរៀន មានវេយ្យាករណ៍បាលីសំស្ក្រឹតជាដើម ទាំងអក្សរសាស្ត្ររបស់ជាតិ និងពាក្យពេចន៍ក្នុងផ្នែកវប្បធម៌បុរាណក៏សម្ដេចចេះចាំយល់ហេតុផល ជាច្រើនណាស់។ ភាសាសៀម ភាសាលាវ និងភាសាបារាំង ដែលសម្ដេចបានរៀន អាចនិយាយប្រាស្រ័យទាក់ទងនឹងជនជាតិសៀម ជាតិលាវ និងជាតិបារាំងបាន។ សម្ដេចឈ្លាសវៃប្រែសព្ទយកតម្រាប់តាមសំឡេងភាសាជាតិដទៃៗឲ្យស្រដៀង ឬដូចភាសាជាតិដទៃបាន។ ភាសាអង់គ្លេស និងភាសាវៀតណាម ក៏សម្ដេចបានរៀន អាចមើល សរសេរនិយាយ ប្រាស្រ័យបានច្រើនដែរ។*

*ក្នុងសម័យដែលសម្ដេចកំពុងសិក្សាវិជ្ជាខាងបាលី ក្នុងរវាងគ.ស.១៩១០ ឃើញថាសម្ដេចមានព្រះកិត្តិស័ព្ទល្បីថា ជាព្រះថេរៈស្ទាត់ជំនាញពូកែខាងភាសាបាលី អាចនិយាយភាសាបាលីបានជាងភិក្ខុ សាមណេរឯទៀត ដែលរៀនជាមួយគ្នាក្នុងសម័យនោះ។*

- *នៅព.ស.២៤៥៧ គ.ស.១៩១៣ សម្ដេចទ្រង់បានចូលប្រឡងដេញប្រយោគក្នុងព្រះឧបោសថរតនារាម វិហារព្រះកែវមរកត ចំពោះព្រះភ័ក្ត្រព្រះករុណាព្រះបាទសម្ដេចព្រះស៊ីសុវត្ថិបាន៤ប្រយោគ ដែលជាប្រយោគជាន់ខ្ពស់បំផុតក្នុងសម័យនោះ។*
- *ព.ស.២៤៥៩ គ.ស.១៩១៥សម្ដេចទ្រង់បានប្រឡងជាប់លេខ២ បានទទួលការតែងតាំងជាសាស្ត្រាចារ្យនៅសាលាបាលីជាន់ខ្ពស់ ដែលសព្វថ្ងៃមានឈ្មោះជាពុទ្ធិកវិទ្យាល័យសុរាម្រឹត។*
- *ក្រៅពីភាសាខ្មែរ ដែលសម្ដេចទ្រង់បានស្រាវជ្រាវយល់ឫសគល់ពិតប្រាកដ សម្ដេចបានសិក្សាភាសាបាលី អាចអាន ឬសន្ទនាតាមសំនៀងជាតិបរទេសបានទាំងអស់ គឺសំនៀងលង្កា ភូមា មន សៀម និងលាវ ឥតមានទើសទាក់ភ្លាំងភ្លាត់ឡើយ។*
- *ព.ស.២៤៦៦ និង២៤៦៧ គ.ស.១៩២២ និង១៩២៣ សម្ដេចកាលនៅជាព្រះគ្រូសង្ឃសត្ថា (ជាមួយនឹងសម្ដេចព្រះពោធិវ័ង្ស ហួត តាត វជិរប្បញ្ញោ កាលនៅជាព្រះគ្រូសង្ឃវិជ្ជា) បានធ្វើជាសមណៈសិស្ស និមន្តទៅបំពេញវិជ្ជាខាងភាសាសំស្ក្រឹត និងអក្សរសិលាចារឹកជាដើម នៅសាលាបារាំងសែសចុងបូព៌ាប្រទេស នាក្រុងហាណូយ (វៀតណាមខាងជើង) ក្នុងសំណាក់លោក ល្វី ហ្វីណូត៍ (L. Finot) ជាតិបារាំងសែស ជាចាងហ្វាងសាលានេះ។*

## ៦. បេសកកម្មបរិច្ឆេទ (កំណត់អំពីការទទួលបម្រើកិច្ចការ)

- *ព.ស.២៤៦៣ គ.ស.១៩១៩សម្តេចទ្រង់បានធ្វើជាសមាជិកនៃក្រុមជំនុំតែងវចនានុក្រមខ្មែរ ដែលទ្រង់ជាលេខាធិការកាន់កិច្ចការផ្ទាល់ លុះត្រាបានចប់ចុងចប់ដើម។*
- *ព.ស.២៤៦៩ គ.ស.១៩២៥សម្តេចបានធ្វើជាសមាជិក នៃក្រុមជំនុំពិនិត្យអក្ខរាវិរុទ្ធនៃសៀវភៅនានា ដែលសាលាបាលីជាន់ខ្ពស់ បោះពុម្ពផ្សាយ។*
- *ព.ស.២៤៧០ គ.ស.១៩២៦ តមកជាច្រើនឆ្នាំ សម្តេចបានទទួលការតែងតាំងជាមេប្រយោគ ក្នុងការប្រឡងយកវិញ្ញាបនប័ត្របឋមសិក្សាខ្មែរ និងការប្រឡងយកសញ្ញាប័ត្របឋមសិក្សាជាន់ខ្ពស់ បារាំង-ខ្មែរ នៅក្រុងភ្នំពេញ។*
- *ព.ស.២៤៧១ គ.ស.១៩២៧ សម្តេចទ្រង់បានទទួលការតែងតាំងជាសមាជិក នៃក្រុមជំនុំផ្ទៀងសម្រេចខាងវចនានុក្រមខ្មែរ ហើយសម្តេចទ្រង់បានទទួលភារៈធ្វើវចនានុក្រម តែមួយព្រះអង្គឯង ដរាបដល់បានចប់សព្វគ្រប់ បានបោះពុម្ពផ្សាយទាំងភាគ១ភាគ២ បាន៥គ្រាហើយ។*
- *ក្នុងឆ្នាំដដែលនេះ សម្តេចទ្រង់បានទទួលការតែងតាំងជា សមាជិកនៃក្រុមអភិបាលជំនុំផ្គាប់ឆ្នាំ សម្រាប់បណ្ណាល័យកម្ពុជា ដែលសព្វថ្ងៃហៅថា វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ។*
- *ព.ស.២៤៧៤ គ.ស.១៩៣០ សម្តេចទ្រង់បានទទួលការតែងតាំង ក្នុងមុខងារជាចាងហ្វាងរង នៃសាលាបាលីជាន់ខ្ពស់ ក្រុងភ្នំពេញ។*
- *ក្នុងឆ្នាំដដែលនោះ សម្តេចទ្រង់បានទទួលការតែងតាំងជា សមាជិកជំនួយនៃ ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ។*
- *ព.ស.២៤៧៦ គ.ស.១៩៣២ សម្តេចទ្រង់បានទទួលការតែងតាំងជាសមាជិកនៃក្រុមជំនុំខាងការ ស្រាវជ្រាវជ្រើសរើសរកពាក្យពេចន៍ក្នុងផ្ទៃ នៃកវីនិពន្ធខ្មែរបុរាណ ដើម្បីប្រមូលបញ្ចូលពាក្យទាំងនេះ ទៅក្នុងវចនានុក្រមខ្មែរ។*
- ព.ស.២៤៧៧ គ.ស.១៩៣៣ សម្តេចទ្រង់បានទទួល ការតែងតាំងជាសមាជិក នៃក្រុមជំនុំពិនិត្យសៀវភៅដែលក្រសួងសិក្សាធិការជាតិបោះពុម្ព ផ្សាយ។
- *ព.ស.២៤៧៨ គ.ស.១៩៣៤ សម្តេចទ្រង់បានទទួលការតែងតាំងជាសមាជិកនៃក្រុមជំនុំជ្រើសរើស ពាក្យខ្មែរប្រៀបធៀបនឹងពាក្យបារាំងសម្រាប់ប្រើក្នុងកិច្ចការ រាជការ។*
- *ព.ស.២៤៧៩ គ.ស.១៩៣៥សម្តេចទ្រង់បានទទួលការតែងតាំងជាសាស្ត្រាចារ្យបង្រៀនភាសាបាលី សំស្ក្រឹត ខ្មែរ និងលាវ ប្រចាំថ្នាក់ទីបំផុតនៃមធ្យមសិក្សា នៅវិទ្យាល័យព្រះស៊ីសុវត្ថិ ក្រុងភ្នំពេញ។*

## ៧. ឋានន្តរបរិច្ឆេទ (កំណត់អំពីឋានន្តរ)

- ព.ស.២៤៨៦ គ.ស.១៩៤២ សម្តេចទ្រង់បានទទួលឋានន្តរ ជាចាង់ហ្វាង់នៃ សាលាបាលីជាន់ខ្ពស់ ក្រុងភ្នំពេញ ដែលសព្វថ្ងៃកែប្រែឈ្មោះជាពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត។
- ព.ស.២៤៨៨ គ.ស.១៩៤៤ សម្តេចទ្រង់បានទទួលតំណែងជាចៅអធិការវត្តឧណ្ណាលោម។
- ព.ស.២៤៨៩ គ.ស.១៩៤៥ សម្តេចទ្រង់បានទទួលនាទីជាអធិបតីនៃថេរសភា គឺក្រុមជំនុំជាន់ខ្ពស់របស់សង្ឃ។
- ព.ស.២៤៩១ គ.ស.១៩៤៧ សម្តេចទ្រង់បានទទួលនាទីជាអនុប្រធានគណៈកម្មការវប្បធម៌ផ្នែកអក្សរ ក នៃគណៈកម្មការជាតិខាងការសិក្សា។
- ព.ស.២៤៩២ គ.ស.១៩៤៨ សម្តេចទ្រង់បានទទួលនាទីជាប្រធានគណៈកម្មការធម្មវិន័យពិនិត្យការផ្សាយសៀវភៅសម្រាប់សាលាធម្មវិន័យក្នុងព្រះរាជាណាចក្រ។
- គ.ស.១៩៦១ រហូតមក សម្តេចទ្រង់ព្រោសមេត្តាទទួលនិមន្តរបស់សមាគមអ្នកនិពន្ធខ្មែរធ្វើ ជាព្រះប្រធាននៃការសម្ភាសអក្សរសាស្ត្រ ផ្សាយតាមវិទ្យុជាតិរៀងរាល់ថ្ងៃសុក្រ។
- គ.ស.១៩៦៨ ទ្រង់ទទួលឋានៈជាប្រធានគណៈកម្មការពិនិត្យអត្ថបទផ្សាយជារឿងខាងប្រវត្តិសាស្ត្រខ្មែរ។
- គ.ស.១៩៦៩ ព្រះអង្គទ្រង់ទទួលការតែងតាំងជាប្រធានគណៈកម្មការពិនិត្យ និងកំណត់អំពីន័យរបស់ទង់ជាតិខ្មែរ។
- ព្រះកិច្ចការដែលសម្តេចទ្រង់បានបំពេញក្នុងព្រះពុទ្ធសាសនានៅបរទេស
- នៅព.ស.២៤៧៥ គ.ស.១៩៣១ សម្តេចទ្រង់បានដឹកនាំគណៈប្រតិភូនៃមន្ត្រីសង្ឃ ទៅកាន់ក្រុងវៀងច័ន្ទន៍ និងក្រុងហ្លួងព្រះបាង ប្រទេសលាវ ដើម្បីរួបរួមក្នុងពិធីសម្ពោធពុទ្ធសាសនបណ្ឌិត្យប្រទេសលាវផង ដើម្បីជំនុំពិភាក្សាអំពីការសិក្សាសម្រាប់សាលាបាលីរងនៅប្រទេសលាវ ផង។
- ព.ស.២៤៧៧ គ.ស.១៩៣៣ សម្តេចទ្រង់បានដឹកនាំ គណៈប្រតិភូព្រះសង្ឃខ្មែរទៅធ្វើទស្សនាចរណ៍ចំពោះវត្តខ្មែរទាំងឡាយ ក្នុងដែនកូសាំងស៊ីន កម្ពុជាក្រោម។
- នៅព.ស.២៤៨៣ គ.ស.១៩៣៩ សម្តេចទ្រង់បានដឹកនាំគណៈប្រតិភូមួយទៅកាន់ប្រទេសលាវម្តងទៀត ដើម្បីប្រជុំប្រឹក្សាកិច្ចការ នៃពុទ្ធសាសនបណ្ឌិត្យប្រទេសលាវ និងការសិក្សាសម្រាប់សាលាបាលីនៅប្រទេសលាវផង ដើម្បីជួយរំលឹកដាស់តឿនប្រជាជាតិលាវឲ្យមានការសិក្សាព្រះ បរិយត្តធម៌ និងការប្រតិបត្តិព្រះពុទ្ធសាសនា ឲ្យស្របគ្នាតាមរបៀបការសិក្សា និងការប្រតិបត្តិព្រះពុទ្ធសាសនានៃប្រទេសកម្ពុជា ទាំងប្រជាជាតិនៅក្នុងទីប្រជុំជន និងក្នុងខេត្តនានា នៃព្រះរាជាណាចក្រលាវ ខំប្រឹងយកចិត្តទុកដាក់ក្នុងការសិក្សា និងការប្រតិបត្តិឲ្យបានត្រឹមត្រូវតាមគន្លងព្រះពុទ្ធសាសនាផង។
- ព.ស.២៤៨៧ គ.ស.១៩៤៣ សម្តេចទ្រង់បានទទួលនាទីជាសមាជិកឆ្លើយឆ្លងនៃសាលាបារាំងសែសនៅចុង បូព៌ាប្រទេស ហើយនៅព.ស.២៤៩២ គ.ស.១៩៤៨ សម្តេចបានទ្រង់ទទួលនាទីជាសមាជិកកិត្តិយសនៃសាលានេះដរាបមក។

- ព.ស.២៤៩៤ គ.ស.១៩៥០ សម្តេចបានទ្រង់ដឹកនាំគណៈប្រតិភូខ្មែរនៅប្រជុំសន្និសីទដើម្បី បង្កើតពុទ្ធិកសមាគមពិភពលោកនៅក្រុងកោលម្បូ ប្រទេសស្រីលង្កាទ្វីប។
- នៅព.ស.២៤៩៧ គ.ស.១៩៥៣ សម្តេចបានទ្រង់ដឹកនាំគណៈប្រតិភូខ្មែរទៅបំពេញបេសកកម្មសុធន្នៈ ប្រឹក្សាសម្រេចរឿងឆដ្ឋសង្គាយនា នៅក្រុងរង្គូន សហភាពភូមា។
- ក្នុងឆ្នាំជាបន្ទាប់នៅព.ស.២៤៩៨ គ.ស.១៩៥៤ សម្តេចបានទ្រង់ដឹកនាំគណៈប្រតិភូខ្មែរនិមន្តនៅកាន់ក្រុងរង្គូន ប្រទេសភូមាម្តងទៀត ដើម្បីរួបរួមក្នុងការប្រជុំធ្វើឆដ្ឋសង្គាយនាសម័យប្រជុំដំបូង។
- កន្លងមួយឆ្នាំក្រោយមក ព.ស.២៤៩៩ គ.ស.១៩៥៥ សម្តេចទ្រង់បានដឹកនាំគណៈប្រតិភូខ្មែរទៅកាន់ទីឆដ្ឋសង្គាយនៅក្រុងរង្គូន ប្រទេសភូមា ជាលើកទីបីដើម្បីប្រជុំ ហើយបិទសម័យប្រជុំប្រចាំឆ្នាំ។
- នៅព.ស.២៥០៣ គ.ស.១៩៥៩ សម្តេចទ្រង់បានដឹកនាំគណៈប្រតិភូខ្មែរទៅកាន់ក្រុងជកតា៌ និងក្រុងសឺម៉ារ៉ាំង កោះជ្វា ប្រទេសឥណ្ឌូណេស៊ី ដើម្បីចូលរួមក្នុងពិធីបុណ្យវិសាខបូជា។
- ព.ស.២៥០៣ ចូលរួមពិធីបញ្ចុះខណ្ឌសីមា និងពិធីសន្មតពេងឧបោសថ ព្រមទាំងជាព្រះឧបជ្ឈាយ៍បំបួសកុលបុត្រអ្នកប្រទេសនោះចំនួនបីរូបផង។

## ៨. សមណសក្តិបរិច្ឆេទ (កំណត់អំពីសមណស័ក្តិ)

*ដោយព្រះមហាវិរិយភាពរបស់សម្តេច ដែលទ្រង់បានបំពេញទាំងផ្លូវព្រះពុទ្ធសាសនា ទាំងផ្លូវលោកដែលយើងបានឃើញជាកស្តុតាង សម្តេចក៏បានឡើងសមណស័ក្តិជាលំដាប់លំដោយ ដូចតទៅនេះគឺៈ*

- *ព.ស.២៤៥៤ គ.ស.១៩១០ សម្តេចបានទទួលការតែងតាំងក្នុងសមណស័ក្តិ ជាព្រះបាឡាត់សាក្យបុត្តិយ៍ (បាឡាត់របស់ព្រះសក្យវង្ស នុត វត្តឧណ្ណាលោម)។*
- *ព.ស.២៤៥៦ គ.ស.១៩១២ សម្តេចបានទទួលសមណស័ក្តិជាព្រះគ្រូសង្ឃសត្ថា (ទីឋានានុក្រម សម្រាប់ថ្នាក់ឯករបស់សម្តេចព្រះសង្ឃរាជព្រះនាម ទៀង)។*
- *ព.ស.២៤៧៥ គ.ស.១៩៣១ សម្តេចបានឡើងសមណស័ក្តិជាព្រះសាសនសោភ័ណ (រាជាគណៈកិត្តិយស)។*
- *ព.ស.២៤៨៤ គ.ស.១៩៤០ សម្តេចបានឡើងសមណស័ក្តិជាព្រះពុទ្ធឃោសាចារ្យ (រាជាគណៈថ្នាក់ទី២)។*
- *ព.ស.២៤៨៨ គ.ស.១៩៤៤ សម្តេចបានឡើងជាសមណស័ក្តិជាព្រះពោធិវង្ស (រាជាគណៈថ្នាក់ទី១)។*
- *ព.ស.២៤៩២ គ.ស.១៩៤៨ សម្តេចបានឡើងសមណស័ក្តិខ្ពស់បំផុតជាព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ។*
- *ព.ស.២៤៩៤ គ.ស.១៩៥០ ព្រះករុណាជាអម្ចាស់ជីវិតទ្រង់បានប្រោសប្រទានប្រគេនព្រះឋានៈជា សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ។*
- *លុះដល់មកព.ស.២៤៩៨ គ.ស.១៩៥៤ រដ្ឋាភិបាលសហភាពភូមាបានប្រគេនព្រះឋានៈសម្តេចជា ព្រះអគ្គមហាបណ្ឌិតសហភាពភូមា។*
- *ស្រាប់តែដល់មកព.ស.២៥០១ គ.ស.១៩៥៧ រដ្ឋាភិបាលសហភាពភូមា បានសូមតម្កើងព្រះឋានៈសម្តេចជា ព្រះអភិធជៈមហារដ្ឋគរុ នៃសហភាពភូមាទៀត ដែលជាសមណស័ក្តិដ៏ខ្ពស់បំផុតមានតែមួយអង្គក្នុងសហភាពភូមា។*
- *ខែកុម្ភៈ គ.ស.១៩៦២ អ្នកនិពន្ធខ្មែរទាំងអស់បានថ្វាយព្រះឋានៈព្រះអង្គជា ព្រះអគ្គនិពន្ធអក្សរសាស្ត្រខ្មែរ និងជាសមាជិកកិត្តិយសនៃសមាគមអ្នកនិពន្ធខ្មែរផង។*
- *ព.ស.២៥០៧ គ.ស.១៩៦៣ សម្តេចព្រះ នរោត្តម សីហនុ ព្រះប្រមុខរដ្ឋនៃប្រទេសកម្ពុជា ទ្រង់បានប្រោសប្រទានព្រះឋានៈសម្តេចជា សម្តេចព្រះសង្ឃរាជថ្នាក់ទី១។*
- *ថ្ងៃទី២៨ ឧសភា ១៩៦៧ ទ្រង់បានទទួលសញ្ញាប័ត្របណ្ឌិតអក្សរសាស្ត្រ ពេញលក្ខណៈអំពីសម្តេចព្រះប្រមុខរដ្ឋក្នុងនាមមហាវិទ្យាល័យ អក្សរសាស្ត្រ និងមនុសាស្ត្រ នៃភូមិន្ទសកលវិទ្យាល័យ។*

## ៩. ឥស្សរិយបរិច្ឆេទ (កំណត់អំពីឥស្សរិយយស)

*គ្រឿងឥស្សរិយយសដែលសម្ដេចបានទទួលមានដូចតទៅនេះ គឺ៖*

- *មេដាយអស្សប្ញទ្ធិមុនីសារភណ្ឌ៍ នៅព.ស.២៤៦១ គ.ស.១៩១៧។*
- *មេដាយអស្សប្ញទ្ធិព្រះរាជាណាចក្រកម្ពុជា នៅព.ស.២៤៦៧ គ.ស.១៩៣២។*
- *មេដាយអស្សប្ញទ្ធិដំរីមួយលាន និងស្វេតច្ឆត្រ ប្រទេសលាវ នៅព.ស.២៤៧៦ គ.ស.១៩៣២។*
- *មេដាយសេនានៃបណ្ឌិតសភា សាធារណរដ្ឋបារាំង នៅព.ស.២៤៨១ គ.ស.១៩៣៧។*
- *មេដាយអស្សប្ញទ្ធិជីឡាឡេស្យុងដូណ្ណើរ នៃសាធារណរដ្ឋបារាំង នៅព.ស.២៤៨៦ គ.ស.១៩៤២។*
- *មេដាយសេនា នៃព្រះរាជាណាចក្រកម្ពុជា នៅព.ស.២៤៨៨ គ.ស.១៩៤៤។*
- *មេដាយសេនាជីឡាឡេស្យុងដូណ្ណើរ នៃសាធារណរដ្ឋបារាំង នៅព.ស.២៤៩២ គ.ស.១៩៤៨។*
- *មេដាយមហាសិរីវឌ្ឍន៍ ព្រះរាជាណាចក្រកម្ពុជា នៅព.ស.២៥០៥ គ.ស.១៩៦២។*
- *មេដាយមហាសិរីវឌ្ឍសុវត្ថារា នៅព.ស.២៥០៦ គ.ស.១៩៦៣។*
- *មេដាយជាតូបការ ដែលជាគ្រឿងឥស្សរិយយសធំបំផុត ក្នុងព្រះរាជាណាចក្រកម្ពុជា នៅព.ស.២៥១៣ គ.ស. ១៩៦៩។*

## ១០. ពុទ្ធវឌ្ឍិបរិច្ឆេទ (កំណត់អំពីការធ្វើសេចក្តីចម្រើនក្នុងផ្លូវលោក និងផ្លូវព្រះពុទ្ធសាសនា)

*កិច្ចការ ឯទៀតរបស់សម្តេច ក្រៅពីមុខការខាងសិក្សាដែលសុទ្ធតែជាការមានប្រយោជន៍ជាសាធារណៈ ក្នុងព្រះពុទ្ធសាសនា និងប្រទេសជាតិនោះ នៅមានច្រើនទៅទៀត និយាយដោយសង្ខេបគឺចាប់តាំងពីឆ្នាំឆ្លូវសប្តស័ក ព.ស.២៤៧០ គ.ស.១៩២៤ រៀងមក សម្តេចបានធ្វើការឧបត្ថម្ភវត្តពោធិព្រឹក្ស (ហៅវត្តពោល្យំ) ក្នុង សង្កាត់រលាំងកែន ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដែលមានព្រំប្រទល់ជាប់គ្នានឹងសង្កាត់រកាកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ជាទីជាតិភូមិរបស់សម្តេច ដូចមានសេនាសនភ័ណ្ឌតទៅនេះ៖*

*១. សម្តេចបានជាវដីជុំវិញវត្តចំនួនជាង៣ហិកតា ពង្រីកទីវត្តឲ្យធំទូលាយច្រើនជាងពីដើម។*
*២. បានជួយឧបត្ថម្ភលើកថ្នល់ ភ្ជាប់ពីថ្នល់ជាតិចូលមកវត្តសុរភី និងពោធិព្រឹក្ស រួមចម្ងាយ៣គីឡូម៉ែត្រ។*
*៣. បានស្ថាបនាវិហារបេតុងអារម៉េ សាលាបាលីរង (ពុទ្ធិកបឋមសិក្សា) រៀបចំទីវត្តពោធិព្រឹក្សទាំងមូល ឲ្យមានទេសភាពសមរម្យតាមសម័យនិយម។*
*៤. បាន ស្ថាបនាស្ពានធំមួយ និងស្ពានតូចមួយសុទ្ធតែបេតុងអារម៉េ ឆ្លងស្ទឹងតូចរាំងព្រំប្រទល់ សង្កាត់រលាំងកែន និងសង្កាត់រកាកោះ។*
*៥. បានឧបត្ថម្ភក្នុងការស្ថាបនាសាលាបឋមសិក្សាបំពេញវិជ្ជា សុរភីពោធិព្រឹក្ស៣ខ្នង តាំងពីគ.ស.១៩២៨ រៀងរហូតដល់សាលានេះឡើងដល់ថ្នាក់ឧត្តមដ្ឋាន សម្រាប់កូនចៅអ្នកស្រុកជើងវត្តសុរភី និងវត្តពោធិព្រឹក្ស។*
*៦. បានឧបត្ថម្ភឲ្យគេធ្វើថ្នល់លំមួយ ចាក់ក្រួសបាយក្រៀម ប្រើការបានដោយស្រួល។*
*៧. បានជាវទីដី៣ហិកតាកន្លះទុកដាក់ជាសាសនសម្បត្តិរៀងទៅ។*
*៨. បានស្ថាបនាខ្លោងទ្វាររបងអារម៉េមួយ។*
*៩. បានស្ថាបនា អាវសថសាលា (សាលាសំណាក់) ១ខ្នង។*
*១០. បានចាត់ការឲ្យជីកស្រះមួយទំហំ១០០ម៉ែត្របួនជ្រុង នៅត្រង់ទីថ្នល់បែកចេញពីថ្នល់ជាតិក្នុងសង្កាត់រកាកោះ។*
*១១. បានជួយឧបត្ថម្ភជីកអណ្តូងបុកប្រើស្នប់៣កន្លែង។*
*១២. បានស្ថាបនាគិលានដ្ឋានមួយខ្នង ប្រសូតិគ្រឹះ (មន្ទីរសម្ភព) មួយខ្នង ដោយបេតុងអារម៉េ។*
*១៣. បានធ្វើកំពែងបេតុងអារម៉េ បណ្តោយ១០០ម៉ែត្រ ទទឹង៩២ម៉ែត្រ ព័ទ្ធជុំវិញមន្ទីរពេទ្យទាំងពីរខ្នងនេះ។*
*១៤. បានស្ថាបនាអគារគព្ភិនីសំណាក់ក្នុងកំពែងនោះដែរ។*
*១៥. បានស្ថាបនាអគារបេតុងអារម៉េ២ខ្នង ក្រៅកំពែងនោះសម្រាប់គិលានសមណៈ។*
*១៦. បានចាត់ការឲ្យលើកទំនប់ទឹក១កន្លែងបណ្តោយ៩០០ម៉ែត្រ ទទឹង៨០០ម៉ែត្រ (ដោយ សម្តេចព្រះនរោត្តម សីហនុ ឧបយុវរាជព្រះប្រមុខរដ្ឋ ទ្រង់សព្វព្រះទ័យបានប្រោសប្រទានព្រះរាជានុញ្ញាតឲ្យលើកទំនប់ទឹក នោះ)។*
*១៧. បាន ឧបត្ថម្ភឲ្យវេយ្យាវច្ចករដាំដំណាំលើទីដីខាងលើនេះ ជាប្រយោជន៍ដល់គិលានដ្ឋាន និងប្រសូតិគ្រឹះរបស់សម្តេចទៅក្នុងអនាគតកាល (ស្ថាបនកម្មទាំងនេះនៅក្នុងភូមិស្រែបន្ទាយ សង្កាត់រកាកោះ)។*
*១៨. បានលះបង់ទីដីមួយកន្លែង ដែលសម្តេចបានជាវហើយនោះជូនព្រះរាជរដ្ឋាភិបាលឲ្យស្ថាបនាអគារមណ្ឌលនីតិកម្ម (ប៉ុស្តិប៉ូលីស) និងមន្ទីរាជសហករណ៍។ល។*
*១៩. បានផ្តើមគំនិតធ្វើសមាគមកសាងមន្ទីរពេទ្យព្រះសង្ឃ ក្រុងភ្នំពេញ។*
*២០. បានកសាងវិហារវត្តឧណ្ណាលោម ដែលជាវិហារធំបំផុតជាងវិហារទាំងអស់ក្នុងប្រទេសកម្ពុជា ហើយមានបីជាន់ ក្នុង ព.ស.២៤៩៩ គ.ស.១៩៥៦។*

២១. បានផ្ដើមកសាងព្រះសក្យមុនីចេតិយនៅខាងកើតស្ថានីយ៍រថភ្លើងយានៗ
២២. បានទំនុកបម្រុង ព្រមទាំងចាត់ចែងសមណនិស្សិតបញ្ជូនឲ្យទៅរៀនឯបរទេស មានប្រទេសឥណ្ឌា ភូមាជាដើមៗ
២៣. បានបង្កើតការសិក្សាធម្មវិន័យ ដើម្បីសិក្ខាកាមកុលបុត្រទូទៅពេញប្រទេសកម្ពុជាៗ
២៤. បានបង្កើតការអប់រំយុវជនដោយសីលធម៌ដែលនៅក្នុងវត្តឧណ្ណាលោម ឬវត្តឯទៀតៗ ដែលមានយុវជននៅវត្តជាច្រើននាក់ៗ
២៥. បានផ្ដើមកសាងឈាបនដ្ឋាន ( ទីបូជាសព) ក្នុង វត្តឧណ្ណាលោម ដែលមានលោកអ្នកឧកញ៉ាតេជះ តាន់ ម៉ៅ ជាអ្នកចេញប្រាក់កសាងឲ្យកើតមានក្នុងប្រទេសកម្ពុជាមុនដំបូង បង្អស់ គ.ស.១៩៥៣ៗ
២៦. បាន ផ្ដើមសង់ឧបដ្ឋានសាលាសម្រាប់មន្ត្រីសង្ឃ ដែលនិមន្តមកក្នុងឱកាសអនុសំវច្ឆរមហាសន្និបាត ដើម្បីប្រជុំទទួលភត្តាហារ និងសម្រាប់ភ្ជុំបិណ្ឌដែលគហបតី លី ស៊ុនផន, ឧបាសិកា តាន់ ស៊ីបី ចេញប្រាក់កសាងៗ
២៧. បានបង្កើតឲ្យមានការហាត់រៀនប្រឡងសូត្របាតិមោក្ខបាលីៗ
២៨. បាន រៀបចំតាំងគណៈកម្មការសង្ឃ និងគណៈកម្មការគ្រហស្ថតាមផ្លូវការគ្រប់វត្តទាំងអស់ ដើម្បីរៀបចំទីវត្តឲ្យស្អាតទាំងមានរបៀបរៀបរយ តាំងពីឆ្នាំ១៩៥៥ដរាបមកៗ
ស្នាព្រះហស្តខាងអក្សរសាស្ត្រនៃសម្ដេច

ព្រះសង្ឃរាជ បានកសាងគម្ពីរដីកាជាច្រើនណាស់ ទាំងគម្ពីរស៊ឹករឹត ទាំងសៀវភៅ ជាពិសេស គឺសៀវភៅដែលសម្ដេចប្រមូលរៀបរៀង និងសៀវភៅដែលទ្រង់ប្រែពីបាលីមកជាភាសាខ្មែរ សម្រាប់ពុទ្ធបរិស័ទរៀនសូត្រៗ សៀវភៅខ្លះជាសៀវភៅដែលកម្រនឹងធ្វើកើត ទាំងមានប្រយោជន៍ជាច្រើនណាស់គឺះ

១. វចនានុក្រមខ្មែរ មាន២ភាគ ក្នុងព.ស.២៤៦១ គ.ស.១៩១៧ សៀវភៅនេះបានបោះពុម្ពច្រើនគ្រាមកហើយៗ
២. កច្ចាយនូបត្ថម្ភកៈ (វេយ្យាករណ៍បាលី) មាន២ភាគ តាំងពីព.ស.២៤៦២ គ.ស.១៩១៨ បានបោះពុម្ពច្រើនគ្រាហើយៗ
៣. គហិបដិបត្តិ ក្នុងព.ស.២៤៦៨ គ.ស.១៩២៦ ជាមួយនឹងព្រះឧត្តមមុនី អ៊ុម ស៊ូ និងព្រះពោធិវង្ស ហួត តាត តាមបញ្ជានៃព្រះតេជព្រះគុណព្រះមហាវិមលធម្ម ថោង ( ពុទ្ធសាសនបណ្ឌិត្យ)ៗ
៤. សាមណេរវិន័យ ក្នុងព.ស.២៤៦០ គ.ស.១៩១៧ ជាមួយនឹងព្រះថេរៈទាំងពីរព្រះអង្គខាងលើនេះដែរៗ
៥. បាតិមោក្ខសំវរសង្ខេប ( សម្រាយ) ព.ស.២៤៧០ គ.ស.១៩២៨ បានបោះពុម្ពច្រើនគ្រាហើយៗ មានសៀវភៅឯទៀតៗជាច្រើនដែលជាបន្ទាប់បន្សំៗ
៦. កាព្យលោកធម៌ បោះពុម្ពដំបូងក្នុងព.ស.២៥០០ គ.ស.១៩៥៧ៗ កាព្យនេះទ្រង់តែងកាលនៅជាព្រះគ្រូសង្ឃសត្ថាៗ
៧. នាគោបមាទិកថា ព.ស.២៤៧៥ គ.ស.១៩៣៣ៗ
៨. ព.ស.២៤៨៤ គ.ស.១៩៤១ សម្ដេចបានតែងសុភមង្គលគាថាបាលីបប្យាវត្តា៧គាថា ព្រមទាំងប្រែជាសម្រាយផងសម្រាប់សូត្រថ្វាយសុភមង្គលសួស្តីចំពោះព្រះករុណាជាអម្ចាស់ជីវិត ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុវរ្ម័នៗ
៩. បព្វជ្ជាខន្ធកៈពិស្តារៗ
១០. ចីវរក្ខន្ធៈពិស្តារៗ
១១. អត្ថបទ ផ្សេងៗជាច្រើនក្នុងទស្សនាវដ្ដីកម្ពុជសុរិយារបស់ពុទ្ធសាសន បណ្ឌិត្យ តាំងពីឆ្នាំ១៩២៦ និងឆ្នាំតៗមក ដែលពុំអាចស្រាវជ្រាវមកដាក់ក្នុងទីនេះបានដោយពេលមមាញឹក ព្រមទាំងអត្ថបទធម៌ឯទៀតៗជាច្រើន ដែលបោះពុម្ពចុះក្នុងទស្សនាវដ្ដីពន្លឺពុទ្ធចក្រៗ
១២. បាន ពិនិត្យកែសម្រួលពាក្យពេចន៍របស់គណៈកម្មការខេមរយានកម្ម ដោយព្រះមេត្តាជួយឲ្យគណៈកម្មការនេះជារបស់ក្រសួងអប់រំជាតិ បានរួបរួមបោះពុម្ពជាសៀវភៅទស្សនាវដ្ដីសម្រាប់បង្រៀនសិស្សផ្នែក មធ្យមសិក្សាចេញៗរៀងរាល់

ខែ។ ព្រះកេរ្តិ៍មួយសំខាន់ណាស់ដែលរលឹកឃើញបានរាល់ថ្ងៃ គឺព្រះរាជនិពន្ធទំនុកច្រៀង បទនគររាជ សម្រាប់ភ្លេងជាតិខ្មែរ ទ្រង់បាននិពន្ធពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៤១ និងទំនុក ព្រមទាំងបទ សរភញ្ញ ដែលទ្រង់បាននិពន្ធកាលពីឱកាសបុណ្យពុទ្ធសករាជ២៥០០។

## ព្រះគុណសម្បត្តិនៃសម្តេចព្រះសង្ឃរាជ

ព្រះគុណសម្បត្តិនៃសម្តេចជាអម្ចាស់មានច្រើនយ៉ាងណាស់ ប៉ុន្តែយើងខ្ញុំបានពិចារណាដោយហ្មត់ចត់ ហើយសរសេរបួបរួមប្រមូលយកចំពោះតែគោលធំៗ ដោយសង្ខេបមានប្រាំយ៉ាង ដូចសេចក្តីរៀបរៀងរែកញែកតទៅនេះ៖

១. វីរិយភាពក្នុងការសិក្សា
២. បដិភាណប្បញ្ញា “ ប្រាជ្ញាវាងវៃ”
៣. វេសារជ្ជប្បញ្ញា “ បញ្ញាក្លៀវក្លាអង់អាច”
៤. ធម្មទេសនាកោសល្យ “ ភាពឈ្លាសវៃក្នុងធម្មទេសនា”
៥. បណីតសកម្មភាព “ សកម្មភាពដ៏ប្រសើរ”

## អធិប្បាយពង្រីកសេចក្តីចំពោះគុណសម្បត្តិនីមួយៗ

**១. វីរិយភាពក្នុងការសិក្សា** នៃសម្តេចជាអម្ចាស់ ដែលមនុស្សចាស់ទុំធ្លាប់បានសង្កេតតាំងពីសម្តេចមានព្រះជន្មនៅ ក្មេង គឺតាំងពីនៅជាសាមណេរជរាបមករហូតដល់សម្តេចមានព្រះជន្មជ្រុលចូល មកបច្ឆិមវ័យហើយ ក៏នៅតែព្យាយាមឥតមានបន្ធូរបន្ថយបញ្ឈប់សេចក្តីព្យាយាមនោះឡើយ សូម្បីព្រះអង្គមានសមណៈស័ក្តិដ៏ខ្ពស់បំផុតទីជាសម្តេចព្រះសង្ឃរាជហើយក៏ដោយ។ វីរិយភាព នេះប្រែថា សេចក្តីព្យាយាម ឬថាប្រឹងប្រែង រាប់ថាជាបារមីមួយរបស់ព្រះពោធិសត្វដែលយើងធ្លាប់ចេះដឹងមកហើយ ហៅថា វីរយៈបារមី។

បណ្តាកិច្ចការគ្រប់យ៉ាង រមែងប្រកបដោយឧបសគ្គ គឺធម៌ជាគរឿងរាំងបើមិនច្រើនក៏តិច តែថាបើសេចក្តីព្យាយាម មានកម្លាំងក្លៀវក្លា ក៏អាចពុះពារ**ចំពោះ**ឧបសគ្គនោះបានដោយពិតសម្តេចព្រះសង្ឃរាជទ្រង់មាន វីរយៈធម៌ដ៏រឹងប៉ឹងជាទីបំផុតបានជាព្រះអង្គចេះតែមានជ័យជម្នះសង្កត់ទៅលើឧបសគ្គគ្រប់យ៉ាងបាន ជាដរាប ទោះបីព្រះអង្គហត់នឿយណាស់ ប៉ុន្តែព្រះអង្គមិនសូវចេះត្អូញត្អែរឡើយ។ ករណីកិច្ចណាមួយដែលគេត្រូវធ្វើដោយកាយក្តី ដោយវាចាក្តី ដោយចិត្តក្តី អាចសម្រេចទៅបានដោយកម្លាំង នៃសេចក្តីព្យាយាមទាំងអស់។ ឥរិយាបទទាំង៤ គឺការដើរ ឈរ អង្គុយ ដេក ដែលនាំឲ្យសម្រេចប្រយោជន៍ទៅបាន ដ៏ដោយគុណានុភាពនៃសេចក្តីព្យាយាមដែរ។

សម្តេចព្រះសង្ឃរាជ ព្រះអង្គមានវីរិយបារមីដ៏បរិបូណ៌ណាស់ សូម្បីសម្តេចដែលមានព្រះជន្ម៨៦ឆ្នាំហើយ ក៏នៅបំពេញកិច្ចការរបស់ព្រះអង្គឥតមានបន្ធូរបន្ថយព្រះកាយពលឡើយ។ ដូចយ៉ាងព្រះអង្គចាប់ធ្វើវចនានុក្រមខ្មែរ ទ្រង់ឥតមានសំចៃកម្លាំង និងពេលវេលាទេ។ សម្តេចយកពេលយប់ធ្វើជាថ្ងៃ យកពេលថ្ងៃធ្វើជាយប់ ខំប្រឹងសរសេររៀបរៀង តាំងពីព្រលប់រហូតដល់ភ្លឺក៏មាន លុះទ្រង់សោយយាគូរួច ចាប់សរសេរតទៅទៀត ទាល់តែដល់ពេលម៉ោង១១ក៏មាន។ ក្នុងរយៈវេលាយប់មួយ សម្តេចទ្រង់បានផ្ទុំក្នុងរវាង៤ ឬ៥ម៉ោងប៉ុណ្ណោះ។ ការប្រព្រឹត្តដោយសេចក្តីព្យាយាម នៃសម្តេចព្រះសង្ឃរាជនេះជាការកម្រមនុស្សធ្វើបានណាស់។

**២. បដិភាណប្បញ្ញា** “ *បញ្ញាវាងវៃ* ” ប្រាជ្ញាសំដៅយកការចេះដឹងយល់ទូទៅ ឬការយល់ច្បាស់លាស់ចំពោះហេតុការណ៍ផ្សេងៗតាមធម្មតា។ ដែលលោកហៅថា “ បដិភាណប្បញ្ញា” នោះ សំដៅយកប្រាជ្ញាដែលកើតឡើងភ្លាមៗ ហើយអាចឆ្លើយតបវិញបានភ្លាម មិនបាច់គិតគូរអស់វេលាយូរទេ។ ប្រាជ្ញារបស់សម្តេចកើតឡើងរហ័សក្នុងពេលដែលគេចោទសួរ ឬនិយាយឲ្យឮភ្លាមក៏អាចដឹងទាន់ចាប់ភ្លឹកនឹកឃើញ ឆ្លើយវិញបានភ្លាម ហាក់ដូចជាបានគូសដៅទុកយូរហើយ។ ប្រាជ្ញាស្មារតីរហ័សវាងវៃ ប្រកបដោយសមត្ថភាព ឆាប់យល់ហេតុការណ៍គ្រប់យ៉ាង ដែលអាចដឹងទាន់ភ្លាមៗ ដូចអធិប្បាយដោយសង្ខេបមកនេះ ហៅថា “ បដិភាណប្បញ្ញា” ។

*សម្តេចព្រះសង្ឃរាជ មានបដិភាណប្បញ្ញានេះបរិបូណ៌ណាស់ ដូចយ៉ាង សម្តេចដែលបានទ្រង់យាងទៅកាន់ទីប្រជុំណាមួយ ដែលមានសមាជិកជាន់ខ្ពស់ ហើយគេត្រូវសាកសួរនិយាយពិភាក្សាការណ៍ជាចាំបាច់ ដែលទាក់ទងមកលើសម្តេចភ្លាម ទ្រង់ក៏អាចឆ្លើយដោះស្រាយទាន់បានភ្លាមវិញដែរ។*

**៣. វេសារជ្ជប្បញ្ញា** “ *បញ្ញាអង់អាច ក្លៀវក្លា* ” *ភាពនៃប្រាជ្ញាអង់អាចក្លៀវក្លានេះ ជាគុណសម្បត្តិមួយដ៏ប្រសើររបស់មនុស្ស។ ប្រាជ្ញារបស់សម្តេចព្រះសង្ឃរាជជាអម្ចាស់របស់យើង រាប់ថាជាប្រាជ្ញាមួយដ៏ខ្ពង់ខ្ពស់ អាចពោលបានថា សម្តេចមានវេសារជ្ជប្បញ្ញាគ្រប់គ្រាន់ ព្រោះព្រះអង្គបានទទួលព្រះកិត្តិនាមដ៏ខ្ទរខ្ទាយទៅក្នុងប្រទេស និងក្រៅប្រទេស។ ដូចយ៉ាងសម្តេចទ្រង់យ៉ាងទៅកាន់ទីប្រជុំធំៗក្នុងប្រទេសដទៃ ព្រះអង្គតែងបន្លឺសីហនាទ ប្រកបដោយប្រាជ្ញាដ៏ក្លៀវក្លា អង់អាចឥតញាប់ញ័រតក់ស្លុតចំពោះទីប្រជុំនោះឡើយ។*

*ប្រាជ្ញាដែលក្លៀវក្លាអង់អាច ដូចអធិប្បាយដោយសង្ខេបមកនេះហៅថា “ វេសារជ្ជប្បញ្ញា” ។*

**៤. ធម្មទេសនាកោសល្យ** “ *ភាពឈ្លាសវៃក្នុងធម្មទេសនា* ”

*ភាពនៃការឈ្លាសវៃមានច្រើនយ៉ាង គឺឈ្លាសវៃក្នុងអំពើបាបក៏មាន ក្នុងអំពើបុណ្យក៏មានឈ្លាសវៃក្នុងអំពើឥតប្រយោជន៍ក៏មាន ក្នុងអំពើមានប្រយោជន៍ក៏មាន។ ការឈ្លាសវៃក្នុងទីនេះសំដៅយកហេតុការណ៍ដែលមានប្រយោជន៍ចំពោះមនុស្សក្នុងបច្ចុប្បន្ន និងក្នុងអនាគត។ ដែលហៅថា “ ធម្មទេសនាកោសល្យ” សំដៅយកការឈ្លាសវៃក្នុងធម្មទេសនា។ សម្តេចព្រះសង្ឃរាជទ្រង់មានភាពឈ្លាសវៃក្នុងធម្មទេសនាដោយ គ្រប់គ្រាន់។*

*ធម្មទេសនានៃសម្តេចប្រកបដោយប្រយោជន៍ទាំងផ្លូវលោក ទាំងផ្លូវធម៌ អាចបំភ្លឺពុទ្ធបរិស័ទប្រជាពលរដ្ឋឲ្យយល់ផ្លូវខុសផ្លូវត្រូវ ឲ្យជឿជាក់ចំពោះជាតិ សាសនា និងព្រះរាជបល្ល័ង្ក។ ព្រះធម្មទេសនា នៃសម្តេចព្រះសង្ឃរាជចាត់ទុកថាជាមូលដ្ឋានមួយដ៏ស្អុកស្កម្ភអាច បំភ្លឺប្រជាពលរដ្ឋឲ្យមានការព្យាយាម មានជំហររឹងប៉ឹង ឲ្យប្រឹងប្រែងប្រកបការងារកុំឲ្យខ្ជិលច្រអូស ឲ្យមានធម៌សាមគ្គី មូលមិត្តជាឯកភាពក្នុងរវាងជាតិ សាសនា និងព្រះរាជបល្ល័ង្ករបស់យើង ដើម្បីឲ្យខ្ពង់ខ្ពស់ថ្កើងរុងរឿងតទៅអនាគត។ ធម្មទេសនានៃសម្តេច ឈ្មោះថាជាធម្មទេសនាទ្រោលបំភ្លឺពុទ្ធបរិស័ទប្រជាពលរដ្ឋឲ្យយល់ប្រយោជន៍គ្រប់យ៉ាង បំភ្លឺទាំងខាងគុណសម្បត្តិ ទាំងគុណវិបត្តិ ជាធម្មទេសនាប្រកបដោយមធ្យោបាយដ៏ប្រសើរវិសេសអាចដឹកនាំចង្អុលបង្ហាញប្រយោជន៍បច្ចុប្បន្ន និងប្រយោជន៍អនាគត ហៅថាជាព្រះធម្មទេសនាដាស់ពុទ្ធបរិស័ទឲ្យភ្ញាក់ខ្លួនក្រោកឡើង ប្រកបការងារដើម្បីឲ្យមានជីវភាពខ្ពង់ខ្ពស់ឲ្យសមគួរដល់កិត្តិយស របស់យើងរាល់គ្នា ជាប្រជាពលរដ្ឋរបស់ប្រទេសឯករាជ្យ ឲ្យចេះឈឺឆ្អាលស្រឡាញ់ជាតិ សាសនា និងព្រះរាជបល្ល័ង្ករបស់យើង។*

*សម្តេចព្រះសង្ឃរាជ មានធម្មទេសនាកោសល្យដ៏បរិបូណ៌។ ធម្មទេសនារបស់សម្តេចគួររាប់ថាជាធម្មទេសនាយឺតយោងស្រោចស្រង់ប្រជាពលរដ្ឋឲ្យមានសតិសម្បជញ្ញៈរឹងប៉ឹង បរិបូណ៌ឡើងទាំងផ្លូវពុទ្ធចក្រ និងផ្លូវអាណាចក្រ ដើម្បីឲ្យចក្រទាំងពីរវិលលឿនទៅស្មើគ្នា។ ធម្មទេសនារបស់សម្តេចគួរលើកថា ជាធម្មទេសនាបើកលោក គឺប្រទេសកម្ពុជាទាំងមូលឲ្យ*

*មានប្រាជ្ញាស្មារតីភ្លឺស្វាង រុងរឿងឡើងដោយពិត ដែលអាចផ្ដល់មធ្យោបាយដ៏ប្រសើរ ឲ្យប្រជាពលរដ្ឋភ្ញាក់ខ្លួនប្រាណចេះជួយខ្លួនដោយខ្លួនឯង។*

*សម្ដេចព្រះសង្ឃរាជ ជាព្រះធម្មកថិកមួយព្រះអង្គយ៉ាងឯក ពុំមានព្រះធម្មកថិកណាមួយប្រៀបស្មើបាយឡើយ។ ធម្មទេសនាដែលពីរោះក្បោះក្បាយប្រកបដោយពាក្យពេចន៍ ប្រយោគមានប្រធានមានរបៀបរៀបរយ មានកម្រងនៃពាក្យសម្ដីដ៏ត្រឹមត្រូវឥតឃ្លៀងឃ្លាត ភ្លាំងភ្លាត់ទាំងប្រកបដោយឧត្ដមគតិ ដៅចំពោះប្រយោជន៍ក្នុងបច្ចុប្បន្ន និងអនាគតដូចសេចក្ដីអធិប្បាយមកនេះហៅថា "ធម្មទេសនាកោសល្យ" ។*

***៥. បណីតសកម្មភាព "សកម្មភាពដ៏ប្រសើរ"***

*ការងាររបស់សម្ដេចព្រអសង្ឃរាជ សុទ្ធតែជាការងារមានប្រយោជន៍ដ៏ឧត្ដុងឧត្ដម ចំពោះពុទ្ធបរិស័ទ ពុំមានការងារណាមួយ ដែលឥតប្រយោជន៍នោះទេ។*

*សម្ដេចបានធ្វើបុណ្យផ្សេងៗជាច្រើនដងណាស់ មានកឋិនទានជាដើម ក្នុងឆ្នាំនីមួយៗបានធ្វើកឋិន២ ឬ៣វត្ត រៀងរាល់ឆ្នាំឥតដែលខានឡើយ។*

*កិច្ចការរបស់សម្ដេចសុទ្ធតែមានគោលដៅឆ្ពោះទៅរកសេចក្ដីសុខ សេចក្ដីចម្រើន ទាំងលោកនេះ ទាំងលោកខាងមុខដោយពិតប្រាកដ សឹងមានភស្តុតាងយ៉ាងជាក់លាក់ក្នុងព្រះរាជជីវប្រវត្តិនេះ។ ចូរមើលបរិច្ឆេទនៃព្រះរាជជីវប្រវត្តិត្រង់បរិច្ឆេទទី៥ ទី៦ និងទី១០។*

*សម្ដេចមានព្រហ្មវិហារដ៏ទូលាយ សង្គ្រោះដល់សាធារណជនមិនត្បិតត្បៀតពេកឡើយ កិច្ចការដែលចេះតែមាន ចេះតែដើរទៅស្រួល មិនចេះឈប់ មិនចេះគាំង នៅថែមទាំងមានប្រយោជន៍ដ៏ខ្ពង់ខ្ពស់ ហៅថា " បណីតសកម្មភាព" ។*

*សកម្មភាពរបស់សម្ដេចព្រះសង្ឃរាជ ប្រកបដោយហេតុផលល្អណាស់ អាចបង្ហាញជាឧទាហរណ៍មួយ ដើម្បីបញ្ជាក់វរជន បញ្ញវន្តទាំងសម័យចាស់ សម័យថ្មីដែលគួរជាទិដ្ឋានុគតិ (ការយកតម្រាប់តាម) បានដោយពិត ដោយហេតុដែលឃើញរូបរាង កិច្ចការជាភស្តុតាងផង ទ្រឹស្តីការងារដ៏ប្រសើរយ៉ាងនេះផងទើបហៅថា "បណីតសកម្មភាព" ។*

## ១១. ចរិតលក្ខណៈបរិច្ឆេទ (កំណត់អំពីលក្ខណៈនៃចរិតប្រក្រតី)

*ការប្រព្រឹត្តជាប់ដោយកាយ វាចា ចិត្តគ្រប់ពេលវេលាយូរៗទៅ អាចជាប់ទៅជាទម្លាប់ ហៅថា " ចរិតប្រក្រតី" ។ ដូចយ៉ាងសម្តីគ្រោតគ្រាត ដែលធ្លាប់និយាយជាប់ជាទំនៀម ហៅថា ចរិតគ្រោតគ្រាត។ ការនិយាយកុហកលេងចំពោះមិត្តសំឡាញ់ យូរៗទៅក៏អាចធ្លាប់មាត់ជាទំនៀម នេះហៅថា ចរិតកុហក។*

*ការជក់បារី ដើមដំបូងឃើញគេជក់ ក៏ជក់លេងតាមគេ យូរៗទៅក៏អាចជាប់ជាទំនៀមជក់បារី។*

*ការដេកថ្ងៃ ដើមដំបូងឃើញគេដេកថ្ងៃ ក៏ដេកតាមគេ លុះដេកថ្ងៃយូរៗទៅក៏អាចក្លាយជាទំនៀម នេះហៅថា ចរិតដេកថ្ងៃ។*

*ការប្រព្រឹត្តិទាល់តែជាប់ប្រយោគ ដែលអាចលះចេញបានដោយកម្រ ដូច្នេះហៅថា " ចរិតប្រក្រតី" សម្តេចព្រះសង្ឃរាជ ព្រះអង្គក៏មានចរិតប្រក្រតីដែរ ប៉ុន្តែចរិតរបស់សម្តេចជាចរិតធូរស្រាល ពុំមែននាំឲ្យខូចខាតពេលវេលា ខូចខាតប្រយោជន៍នោះឡើយ។*

*មនុស្សខ្លះមានចរិតប្រក្រតីជាប់ជោកធ្ងន់ណាស់ ដូចយ៉ាងចរិតប្រក្រតីផឹកស្រាទាល់តែកឹកជាប់ ដែលអាចលះបង់ចេញមិនបាន។ ចរិតប្រក្រតីបែបនេះ ឈ្មោះថាជាចរិតនាំឲ្យខូចខាតទាំងជីវិតខ្លួនឯង ទាំងទ្រព្យសម្បត្តិរបស់ខ្លួន។*

*ការជក់អាភៀន ក៏អាចនាំឲ្យជាប់ញៀន លះចេញបានដោយកម្រណាស់។ ការញៀនអាភៀននេះ ហៅថា ចរិតប្រក្រតីជក់អាភៀន។ មនុស្សអ្នកមានចរិតបែបនេះ នាំឲ្យខូចខាតទាំងជីវិត ទាំងទ្រព្យសម្បត្តិ ជាងចរិតអ្នកផឹកសុរាច្រើនណាស់ទៅទៀត។*

### *ចរិតប្រក្រតីនៃសម្តេចព្រះសង្ឃរាជ*

*១. ព្រះអង្គសោយស្លាម្លូ ជាញឹកញយណាស់ក្នុងថ្ងៃនីមួយៗ មិនសោយបារី។ ប៉ុន្តែលោកអ្នកធ្លាប់ដឹងឃើញនិយាយថា សម្តេចព្រះសង្ឃរាជ កាលពីព្រះជន្មរវាង២០ឆ្នាំ រហូតដល់ព្រះជន្មជាង៣០ឆ្នាំ ឃើញសម្តេចសោយបារីដែរ ប៉ុន្តែសោយរង្វើលៗមិនញឹកញាប់ទេ លុះដល់មកព្រះជន្មរវាង៤០ឆ្នាំ ទើបសម្តេចសោយស្លាម្លូកាន់តែញឹកញាយឡើងដរាបមក។*

*២. សម្តេច កាលបើមានរោគផ្តាសាយ ដែលនាំឲ្យតឹងច្រមុះ និងក្អកដោយរោគផ្តាសាយនោះ ច្រើនតែឃើញសម្តេចសោយថ្នាំចិនញាត់ខ្សៀ ហើយសម្តេចមានបន្ទូលថា រោគផ្តាសាយនេះបានតែជក់ថ្នាំចិន ទើបធាប់ជាសះស្បើយ ថ្នាំចិននេះនាំឲ្យជាឫសដូងច្រមុះថែមទៀត។*

*៣. សម្តេចមានចរិតប្រក្រតី ក្នុងការសោយក្រយាហារ ច្រើនតែសព្វព្រះទ័យនឹងសម្លស្រឡក់ ប្រហើរ និងកកូរ ពុំសូវសោយសាច់ឈាមទេ។ ម្ហូបពុមុខខាងលើនេះ ច្រើនតែឲ្យគេស្ងនឹងត្រីឆ្អើរ បើពុំមានម្ហូបនេះទេ ច្រើនសព្វព្រះទ័យម្ហូបគ្រៀមគ្រោះ មានបុកត្រីឆ្អើរ ម្ទេសក្រសាំង ឬផ្ទៃម្នាក់ជាដើម។ សម្តេច ពុំសូវសោយបង្អែមច្រើនទេ សោយតែបន្តិចបន្តួច មិនសូវសោយកាហ្វេ ទឹកក្រូច ទឹកម៉ាណាត់ញឹកញាយទេ សោយតែទឹកតែ និងស្ករស។*

*៤. សម្តេចសព្វព្រះរាជហឫទ័យនឹងកូនឈើផ្សេងៗ ដែលមានមែកច្រើន ដូចយ៉ាងដើមច្រកែង ទួយ រទាំងជាដើម យកមកដាំដាក់ក្នុងផើងជាច្រើន ចំនួនជាង១០០ផើង។*

*៥. ដើមឈើឯទៀតៗ ជាឈើដំណាំស្រុកក្តី ឈើក្នុងព្រៃក្តី សម្តេចសព្វព្រះរាជហឫទ័យដាំច្រើនណាស់ ដូចឈើក្នុងរបងឈាបនដ្ឋានវត្តឧណ្ណាលោម និងឈើវត្តពោធិព្រឹក្ស។*

## កម្មវិធីប្រចាំថ្ងៃរបស់សម្តេច

កម្មវិធីរបស់សម្តេចទៀងទាត់ចំពោះត្រង់តែសោយក្រយាហារពេលថ្ងៃ ត្រង់ ហើយនឹងពេលដែលធ្វើការ ដូចយ៉ាងសម្តេចសរសេរដកស្រង់ធម៌អាថ៌រៀបចំធ្វើសៀវភៅផ្សេងៗ មានវចនានុក្រមខ្មែរជាដើមនេះ ទៀងទាត់រៀងរាល់យប់ទាល់ៗភ្លឺ រវាងម៉ោង៦កន្លះ ឬម៉ោង៧ ទើបសោយយាគូ ជួនកាលពេលព្រឹក មិនទាំងសោយយាគូថែមទៀត ឃើញថាពេលយាគូពុំសូវទៀងទាត់ទេ។

ពេលដែលសម្តេចកំពុងជាប់ព្រះហស្ថសរសេរ ហើយមានភ្ញៀវចូលមកថ្វាយបង្គំគាល់ សម្តេចក៏ចូលមកគាល់ធ្វើបដិសណ្ឋារៈភ្លាមៗ ហើយមិនឲ្យនៅយូរទេ ព្រោះមានកិច្ចការច្រើនណាស់ បើថ្ងៃណាមួយដែលសម្តេចទំនេរមិនមានកិច្ចការ ហើយមានភ្ញៀវ បព្វជិត ឬគ្រហស្ថចូលមកថ្វាយបង្គំគាល់នោះ សម្តេចសព្វព្រះរាជហឫទ័យប្រាស្រ័យទាក់ទង ដោយព្រះរាជឱង្ការសាកសួរពីនេះ ពីនោះ ហើយទ្រង់ដឹកនាំបំភ្លឺអំពីផ្លូវលោក ផ្លូវសាសនាយ៉ាងពិស្តារ វែងឆ្ងាយណាស់អស់៤-៥ម៉ោងក៏មាន ទាល់តែភ្លឺក៏មាន មិនចេះត្អូញថាផ្ងុយសឹង ថាពុករួយស្រពន់ទេ ឲ្យតែភ្ញៀវនោះទ្រាំអង្គុយចូលចិត្តស្តាប់ចុះ។ ការណ៍នេះ ចំពោះតែពេលណាមួយដែលសម្តេចមានព្រះសុខភាពរាងកាយស្រួលល្អ។

ក្នុងថ្ងៃយប់នីមួយៗ សម្តេចព្រះសង្ឃរាជ ចេះតែមានកម្មវិធីជានិច្ចកាល ដូចយ៉ាងកាលសម្តេចនៅក្នុងរវាងព្រះជន្ម៣០ឆ្នាំ រហូតដល់មកព្រះជន្មជាង៦០ឆ្នាំ ក៏នៅតែខំប្រឹងបង្រៀនភិក្ខុ សាមណេរចំនួន២០ ឬ៣០អង្គក្នុងពេលយប់ៗ ចំពោះភិក្ខុ សាមណេរនៅក្នុងកុដិរបស់ព្រះអង្គខ្លះ មកពីកុដិដទៃខ្លះ។ សម្តេចមានកម្មវិធីចំពោះពេលបង្រៀននោះទៀងទាត់ណាស់ កម្មវិធីដែលត្រូវបង្រៀនក្នុងសាលាបាលីជាន់ខ្ពស់ ដែលឥឡូវនេះហៅថាពុទ្ធិកវិទ្យាល័យសុរាម្រឹតផង កម្មវិធីបង្រៀនក្នុងពេលយប់ឯកុដិនោះផង។

## អព្ភូតហេតុមុនពេលដែលព្រះសង្ឃរាជព្រះអាពាធ

នៅថ្ងៃពុធ ១៣រោច ខែស្រាពណ៍ ត្រូវនឹងថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៦៩ សម្តេចព្រះសង្ឃរាជមានព្រះឱង្ការថា “ ខ្ញុំពីយប់មិញសុបិននិមិត្តមួយចំឡែកណាស់ គឺឃើញចេតិយពីរលើអាកាស មកអំពីទិសពាយ័ព្យសានតម្រង់មករកខ្ញុំដែលកំពុងអង្គុយនៅយ៉កុដិខាងមុខ ចេតិយនោះ មានពណ៌ដូចមាស លុះអណ្តែតចូលមកជិត ឃើញចេតិយនោះកាន់តែតូច ហើយបាត់មួយ នៅតែមួយអណ្តែតមកជិតអាត្មា អាត្មាក៏លូកដៃទៅទ្រចេតិយនោះ រួចក៏ភ្ញាក់ខ្លួនព្រឺតឡើង ក្នុងពេលជិតភ្លឺរវាងម៉ោង៤។ ព្រះឱង្ការ សម្តេចព្រះសង្ឃរាជនេះ ក្នុងពេលប្រជុំសង្ឃ ដើម្បីតាំងគណៈកម្មការធម្មវិន័យ ក្នុងថ្ងៃ២កើត ខែភទ្របទ ត្រូវនឹងថ្ងៃទី១៣ ខែកញ្ញាឆ្នាំ១៩៦៩។ បន្ទាប់មកទៀតសម្តេចមានព្រះឱង្ការថា អង្គការធម្មវិន័យរបស់យើងនៅខ្វះសៀវភៅធម៌ជាច្រើនមុខ ព្រោះហេតុនោះយើងត្រូវតាំងគណៈកម្មការជាថ្មីទៀត ដើម្បីប្រជុំគ្នារៀបចំធ្វើសៀវភៅធម៌ ត្រូវដកស្រង់ធម៌វិន័យ អំពីបាលី និងអដ្ឋកថា មករៀបរៀងអត្ថាធិប្បាយ តម្រូវតាមថ្នាក់ត្រី ទោ ឯក។

“ត្រង់ដែលអាត្មាយល់សប្តិឃើញចេតិយនោះ ប្រហែលជានិមិត្តមួយប្រផ្នូលឲ្យយើងដឹងថាគណៈកម្មការធម្មវិន័យ របស់យើងនឹងបានសម្រេចដោយល្អ” ។ ព្រះសុបិននិមិត្ត នៃសម្តេចដែលឃើញចេតិយមួយគូនេះ ទុកជាអព្ភូតហេតុមួយដ៏អស្ចារ្យចម្លែកណាស់។

អព្ភូតហេតុមួយទៀត នៅថ្ងៃ១៣កើត និង១៤កើត ខែភទ្របទ ត្រូវនឹងថ្ងៃទី២៤ និង២៥ ខែកញ្ញា ឆ្នាំ១៩៦៩ នៅវេលាយប់ពីម៉ោង២០ទៅម៉ោង២២ ឃើញព្រះច័ន្ទមានរស្មីលឿង ខៀវ ក្រហម មានរង្វង់មូលព័ទ្ធជុំវិញព្រះច័ន្ទ ដែលយើងធ្លាប់ហៅថាព្រះច័ន្ទបាំងឆ័ត្រ។

## ១២. ជីវិតាវសានបរិច្ឆេទ (កំណាត់អំពីទីបំផុតនៃព្រះជីវិត)

*រាប់តាំងពីថ្ងៃ១៣រោច ខែស្រាពណ៍ ជាថ្ងៃដែលទ្រង់ឃើញសុបិននិមិត្ត រហូតមកដល់ថ្ងៃ១២កើត ខែភទ្របទ គឺត្រូវនឹងថ្ងៃទី១០ ខែកញ្ញា មកដល់ថ្ងៃទី២៣ កញ្ញា ត្រូវជា១៤ថ្ងៃ គឺសម្ដេចចាប់មានអាពាធ ក្នុងថ្ងៃ១២កើត ខែភទ្របទ ឆ្នាំរកា ឯកស័ក ព.ស. ២៥១៣ ត្រូវនឹងថ្ងៃទី២៣ កញ្ញា ឆ្នាំ១៩៦៩ វេលាម៉ោង១៥ និង៤៥នាទី។*

*ព្រះសង្ឃដែលធ្លាប់ចូលគាល់បម្រើព្រះអង្គ នាំគ្នាអង្គុយនៅក្រៅបន្ទប់ក្រឡាព្រះបន្ទំ ស្រាប់តែឮសូរកណ្ដឹងរោទ៍ប្លែកពីធម្មតា ក៏នាំគ្នាស្ទុះចូលទៅក្នុងក្រឡាព្រះបន្ទំភ្លាម។ គ្រានោះសម្ដេចមានព្រះឱង្ការថា " អាត្មាចុកទ្រូងណាស់!"។ ក្នុងពេលនោះ ព្រះសង្ឃដែលនៅកំដរនោះ ក៏ជំនុំពិគ្រោះគ្នាឲ្យព្រះសិរីវិសុទ្ធ ម៉ី យ៉ាំ និយាយទូរស័ព្ទទៅលោកវេជ្ជបណ្ឌិត ថោ ប៉េងថុង ទៅក្រសួងធម្មការ។ គ្រូពេទ្យជាច្រើននាក់ គឺលោក វេជ្ជបណ្ឌិត ថោ ប៉េងថុង, មី សាម៉ឺឌី, យូ គឹមយាន, ព្រំ ភួន, រស សារី, និងលោកវេជ្ជបណ្ឌិត ម៉ា ហ្សូ ជាតិបារាំង ក៏បានមកជាបន្ទាប់គ្នា ពិនិត្យឃើញថាអាការរោគនៃសម្ដេចមិនទាន់ធ្ងន់ធ្ងរប៉ុន្មានទេ ប៉ុន្តែទោះបីជាយ៉ាងណា ក្រសួងសុខាភិបាលក៏បានចាត់លោកគ្រូពេទ្យ យូ គឹមយាន និងលី គឹមសាន ឲ្យមកនៅរក្សាព្រះរោគប្រចាំការ ប្រកបឱសថថ្វាយជាជរាបរហូតដល់ថ្ងៃព្រហស្បតិ៍ ១៤កើត ខែភទ្របទ ត្រូវនឹងថ្ងៃ២៥ កញ្ញា ១៩៦៩ វេលាម៉ោង២០និង ២០នាទី ស្រាប់តែព្រះអស្សាសៈ បស្សាសៈ នៃព្រះអង្គរលត់ស្ងប់ឈឹង អំពីព្រះកាយទ្រង់សោយទិវង្គត ក្នុងគម្រប់ព្រះជន្ម៨៦ ព្រះវស្សា នៅលើព្រះទែនសយនា ដោយស្ងប់ស្ងៀមនាល្វែងធំ នៅក្នុងព្រះរាជដំណាក់ព្រះអង្គ កណ្ដាលពួកថេរានុត្ថេរៈ មានព្រះសិរីវិសុទ្ធ ម៉ីយ៉ាំ និងព្រះឥន្ទមុនី ឆាយ ថន ជាដើម នាវត្តឧណ្ណាលោម។ ក្នុងពេលដែលសម្ដេចព្រះសង្ឃរាជសោយទិវង្គតភ្លាមនោះ ព្រះសង្ឃច្រើនអង្គ មានព្រះសិរីវិសុទ្ធ ម៉ីយ៉ាំ និងព្រះឥន្ទមុនី ឆាយ ថន ជាដើម ព្រមទាំងលោក ម៉ា អុក គិលានុបដ្ឋាក ក៏នៅកំដរជាមួយដែរ មានចិត្តរំជួល ញាប់ញ័រ ស្រឡាំងកាំង ស្ទើរតាន់តាំងស្មារតី បានចាត់ការផ្សាយដំណឹងទិវង្គត ដល់ព្រះសង្ឃក្នុងវត្តភ្លាម អង្គខ្លះក៏រត់ទៅប្រគេនដំណឹងនេះដល់ សម្ដេចព្រះពោធិវង្ស។ ព្រះសិរីវិសុទ្ធ ម៉ីយ៉ាំ ក៏ទូរស័ព្ទទៅលោកវេជ្ជបណ្ឌិត ថោ ប៉េងថុង ទៅព្រះរាជដំណាក់ចម្ការមន ទៅក្រសួងធម្មការ ទៅសាលាក្រុង ទៅស្នងការដ្ឋានប៉ូលីសភ្លាម លោកអង្គខ្លះក៏យកដំណឹងទៅវត្តឯទៀតៗក្នុងក្រុងភ្នំពេញ។*

*បន្ទាប់ពីបានដំណឹងនៃការសោយព្រះទិវង្គតនៃសម្ដេចព្រះសង្ឃរាជជា អម្ចាស់ភ្លាម ក្នុងរាត្រីនោះ សម្ដេចព្រះប្រមុខរដ្ឋទ្រង់បានស្ដេចយាងលេះលាំងមកកាន់មហាកុដិ វត្តឧណ្ណាលោមភ្លាម ដើម្បីក្រាបថ្វាយបង្គំព្រះបរមសព។ សម្ដេចព្រះពោធិវង្ស ក៏និមន្តមកគង់នៅជិតព្រះបរមសព តាំងពីពេលមុនសម្ដែងព្រះសមានទុក្ខសោកស្ដាយយ៉ាងខ្លាំងចំពោះបរម សព។*

*ដំណាលគ្នានេះ សម្ដេចព្រះមហាក្សត្រីយានី ជាអម្ចាស់ជីវិត ក៏ទ្រង់ចាត់អ្នកអង្គម្ចាស់នាយកក្រសួងនានា ក្នុងព្រះបរមរាជវាំង ជាព្រះរាជតំណាងមកថ្វាយបង្គំព្រះបរមសពដែរ ហើយពេលជាមួយគ្នានោះ ឯកឧត្តម ឧត្តមសេនីយ៍ឯក លន់ នល់ នាយករដ្ឋមន្ត្រី, អង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ ឧបនាយករដ្ឋមន្ត្រីទី១ ព្រមទាំងសមាជិករដ្ឋមន្ត្រី ឧកញ៉ាមហាមន្ត្រី កែ មាស ចាងហ្វាងពិធីការព្រះបរមរាជវាំង និងមន្ត្រីនានាក្នុងព្រះបរមរាជវាំង ឧត្តមសេនីយ៍ឯក ង៉ោ ហ៊ូ ទីប្រឹក្សាសម្ដេចព្រះប្រមុខរដ្ឋ លោក ឌី ទូច រដ្ឋលេខាធិការក្រសួងធម្មការ លោកអ៊ី ទុយ អភិបាល ក្រុងភ្នំពេញ ឯកឧត្តម ទិម ដុង ប្រតិភូរាជរដ្ឋាភិបាលប្រចាំខេត្តកណ្ដាល ព្រមទាំងនាយទាហានជាន់ខ្ពស់ទាំងឡាយ សហជីវិន លាង ហ័បអាន នាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ ក្រុមអភិបាលពុទ្ធិកសមាគមទាំងបី មានលោក ទា ប៊ុនឡុង ជាដើម។*

*អស់លោកអ្នកឥស្សរជនធំតូច ដែលអញ្ជើញមកកាន់វត្តឧណ្ណាលោម ក្នុងវេលារាត្រី១៤កើត ខែភទ្របទ ត្រូវនឹងថ្ងៃទី១៥ ខែកញ្ញានោះ សុទ្ធតែមានមុខស្រពោន ក្រៀមក្រំគ្រប់ៗគ្នា ដោយសេចក្ដីសោកស្ដាយចំពោះសម្ដេចដ៏ក្រៃលែង បានចូលមកសម្ដែងមរណទុក្ខ សោកស្ដាយ ក្រៀមក្រំ រំជួលចំពោះព្រះបរមសព ដោយគ្រប់គ្នាទាំងអស់។*

បន្ទាប់ពីពេលនោះមក ព្រះសង្ឃជាច្រើនអង្គមានព្រះពុទ្ធឃោសាចារ្យ រាជ គីង មេគណក្រុងភ្នំពេញ និងព្រះមុនីកោសល្យ សួរ ហាយ ចៅអធិការវត្តនិពេធរង្សី ជាដើម ព្រមទាំងព្រះរាជាគណៈ និងឋានានុក្រម ជាច្រើនរយអង្គនិមន្តមកព្រោងព្រាត សុទ្ធតែមានមុខក្រៀមក្រំ ស្រងូតស្រងាត់គ្រប់ៗអង្គ ដោយសេចក្ដីស្ដាយស្រណោះអាឡោះអាល័យ ចំពោះសម្ដេចជាអង្គម្ចាស់។

លំដាប់តមកទៀត ក្នុងពេលរាត្រីនោះរវាងម៉ោង២២-២៣ ចេះតែមានពុទ្ធបរិស័ទ ទាំងបព្វជិត ទាំងគ្រហស្ថ និមន្តអញ្ជើញមកកាន់វត្តឧណ្ណាលោមជយៗ នាំគ្នាឈរត្រៀបត្រា ពាសពេញដីបរិវេណព្រះរាជដំណាក់ ទាំងអស់លោកអ្នករាជការក្នុងក្រុងភ្នំពេញ មានលោកអ្នកក្រសួងធម្មការជាដើម បាននាំគ្នាមកជាលំដាប់លំដោយ ចូលក្រាបថ្វាយបង្គំគាល់ព្រះបរមសព សុទ្ធតែមានទឹកមុខជ្រប់ស្រពោនស្មើរតែគ្រប់ៗគ្នា ខ្លះមានជលនេត្រស្រក់សស្រាក់រកហានិយាយស្ដីពុំកើត ពេលជាលំដាប់មកទៀត ចេះតែមានពុទ្ធបរិស័ទ ទាំងគ្រហស្ថ បព្វជិត ធ្វើដំណើរមកកាន់វត្តឧណ្ណាលោម យ៉ាងណែនណាន់តាន់តាប់រហូតទាល់តែភ្លឺ។ លោកអ្នកខ្លះមានទឹកភ្នែកហូររហាម ហើយបន្ទឹវាចារថ្ងូរថា ឱ! សម្ដេចព្រះសង្ឃរាជ ចូលទិវង្គតហើយតើ! សូម្បីព្រះអង្គ មានព្រះជន្ម៨៦ពិតមែន ប៉ុន្តែយើងខ្ញុំព្រះអង្គនៅតែស្ដាយស្រណោះ ចង់ឲ្យសម្ដេចគង់នៅជាងរយព្រះវស្សាដោយយើងខ្ញុំព្រះអង្គធ្លាប់ ស្ដាប់ព្រះរាជឱវាទ ធ្លាប់ឃើញធ្លាប់គោរពសម្ដេចជាអង្គម្ចាស់ ឥឡូវនេះស្រាប់តែសម្ដេចជាអង្គម្ចាស់ចូលទិវង្គត ទៅកាន់បរលោកនាយចោលយើងខ្ញុំទៅហើយ។ ការចូលទិវង្គតនៃសម្ដេចព្រះសង្ឃរាជនេះ នាំឲ្យទូលព្រះបង្គំគ្រប់រូបរហេងរហាងត្រមង់ត្រមោចក្នុងចិត្តអស់សេចក្ដីសង្ឃឹមកក់ក្ដៅចំពោះសម្ដេចទៅ ហើយ។

សម្ដេចព្រះសង្ឃរាជ ដែលព្រះអង្គបានយាងមកសោយ ព្រះជាតិក្នុងប្រទេសកម្ពុជាយើងនេះ ព្រះអង្គបានធ្វើប្រយោជន៍ ទាំងផ្លូវព្រះពុទ្ធសាសនា ទាំងផ្លូវលោក ទុកឲ្យពុទ្ធបរិស័ទជាច្រើនណាស់ ឈ្មោះថាព្រះអង្គបានលើកព្រះពុទ្ធសាសនា លើកប្រទេសជាតិឲ្យបានថ្កុំថ្កើនរុងរឿង រួមជាមួយនឹងសម្ដេចព្រះឧបយុវរាជព្រះប្រមុខរដ្ឋដែលឃើតយោងប្រជា ពលរដ្ឋ ដោយព្រះមធ្យោបាយដ៏ខ្ពង់ខ្ពស់បំផុត ឲ្យប្រទេសជាតិមានឯកភាព សាមគ្គីភាព សន្តិភាព បានឯករាជ្យដ៏បរិបូរណ៍ ដូចសេចក្ដីប្រាថ្នា ហើយយ៉ាងណាសម្ដេចព្រះសង្ឃរាជ មានព្រះរាជជីវប្រវត្តិល្អណាស់ មានព្រះបំណងសម្រេចក៏យ៉ាងនោះដែរ។

ព្រឹកឡើង ថ្ងៃ១៥កើត ខែភទ្របទ (២៦ កញ្ញា) អស់លោកឥស្សរជន បានប្រជុំតាំងគណៈកម្មការមួយបណ្ដោះអាសន្នសម្រាប់ចាត់ការបុណ្យ ព្រះបរមសពតទៅ។

## រយៈកាលមុនអំពីកាលដែលសម្ដេចទ្រង់សោយព្រះទិវង្គត

សម្ដេចព្រះសង្ឃរាជ មានព្រះអាពាធជាដំបូងក្នុងថ្ងៃអង្គារ ១២កើត ខែភទ្របទ ឆ្នាំរកា ឯកស័ក ត្រូវនឹងថ្ងៃ២៣ ខែកញ្ញា ឆ្នាំ ១៩៦៩។ ដំណឹងព្រះអាពាធនៃសម្ដេចព្រះសង្ឃរាជនេះ បានថ្វាយចំពោះសម្ដេចព្រះប្រមុខរដ្ឋរួចហើយ។ ឯកឧត្តម អ៊ឹង ហុងសាធ តាមព្រះរាជបញ្ជានៃសម្ដេចព្រះប្រមុខរដ្ឋ បានចាត់ឲ្យអស់លោកវេជ្ជបណ្ឌិតខ្មែរ បារាំងដ៏ជំនាញៗទាំងឡាយ មកជួយខ្វល់ខ្វាយព្យាបាលរោគព្រះអង្គយ៉ាងពេញសមត្ថភាព ប៉ុន្តែធ្វើម្ដេចឡើយនឹងអាចយកជ័យជម្នះលើមច្ចុសន្ត្រាមបាន។

សម្ដេចព្រះសង្ឃរាជជាអម្ចាស់ទ្រង់បានជ្រាបព្រះអង្គជាមុន ចាប់តាំងពីថ្ងៃប្រឈួន ទ្រង់មានព្រះឱង្ការប្រាប់ព្រះសង្ឃ និងអស់លោកដែលមកថ្វាយបង្គំសាកសួរព្រះសុខភាពថា “អាត្មាមានជំងឺម្ដងនេះ ដូចជាគ្មានសង្ឃឹមទេ” ព្រះរាជឱង្ការនេះ ធ្វើឲ្យយើងរាល់គ្នាមានការព្រួយបារម្ភណាស់ ប៉ុន្តែយើងរាល់គ្នាជឿទុកថា ព្រះអង្គមុខជានឹងគង់ព្រះជន្មាយុតទៅទៀតបាន ពីព្រោះសង្កេតទៅព្រះសរីរាង្គកាយព្រះអង្គ ពុំឃើញមានប្រែប្រួលប្លែកប៉ុន្មានទេ ម្យ៉ាងទៀត ទ្រង់នៅចាំព្រះស្មារតីល្អណាស់ អាចមានព្រះឱង្ការមាំមួន សំណេះសំណាលនឹងអស់លោក ទាំងព្រះសង្ឃ គ្រហស្ថ ដែលមកក្រាបបង្គំគាល់នោះ បានស្រួលនៅឡើយ ជាពិសេសកាលពីព្រឹកនៃថ្ងៃសោយព្រះទិវង្គតនេះឯកឧត្តមនាយក រដ្ឋមន្ត្រី នឹងអ្នកអង្គម្ចាស់ឧបនាយករដ្ឋមន្ត្រីទី១ បានចូល

បង្គំគាល់ព្រះអង្គដើម្បីសាកសួរព្រះរោគព្រះអង្គផង ដើម្បីក្រាបបង្គំលាព្រះអង្គទៅកាន់បរទេសតាមការអញ្ជើញនៃសាធារណរដ្ឋចិនប្រជាមានិត និងសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ផង។

គ្រានោះព្រះអង្គបានទទួលរាក់ទាក់ ហើយបានប្រសិទ្ធពរជូនចំពោះ ឯកឧត្តមនាយករដ្ឋមន្ត្រី និងថ្វាយចំពោះអ្នកអង្គម្ចាស់ឧបនាយករដ្ឋមន្ត្រីទី១ សូមទៅបំពេញបេសកកម្មនៅប្រទេសក្រៅបានជោគជ័យ។ ក្រោយមកទៀតសម្ដេចក៏ព្រះរាជទានសន្ទនាជាមួយលោក ឌី ទូច រដ្ឋលេខាធិការក្រសួងធម្មការ និងលោក ទ្រិញ ហ៊ាញ ប្រធានសមាគមអ្នកនិពន្ធខ្មែរអំពីការធ្វើចេតិយ។ ព្រះអង្គទ្រង់មានព្រះរាជបន្ទូលហូរហែ ហើយទ្រង់និទានអំពីចេតិយឈ្មោះ សិង្គុត្តរៈ នៅសហភាពភូមាថែមទៀតផង។ រួចព្រះអង្គត្រាស់រំលឹកអំពីការបោះពុម្ពវចនានុក្រមខ្មែរដែលទ្រង់ បានខិតខំកែសម្រួលបន្ថែមពាក្យជាច្រើនទៀត ទោះបីជរានិងព្យាធិបេះតែបៀតបៀនព្រះអង្គក៏ដោយ។ សភាពទាំងនេះសឲ្យឃើញថា ព្រះអង្គនៅរឹងប៉ឹងណាស់ មិនគួរឡើយនឹងប្រែប្រួលដោយឆាប់រហ័សដូច្នេះសោះ នាំឲ្យយើងក្រៀមក្រំស្រងោកចិត្តដូចជាយើងធ្លាក់បេះដូង។ នេះហើយសមដូចព្រះថេរដីការបស់ព្រះអង្គ ដែលទ្រង់ត្រាស់ជារឿយៗថា៖ ជួនកាលពេលព្រឹកមនុស្សសត្វជួបគ្នារញ៉េរញ៉ៃ លុះពេលល្ងាចក៏ស្រាប់តែបែកគ្នាភ្លាមៗ។ សភាពនេះត្រូវដូចព្រះតម្រាស់នោះណាស់ ព្រះអង្គយាងទៅចោលពុទ្ធបរិស័ទរាល់គ្នា ឥតមានប្រទានដំណឹងជាមុនឲ្យច្បាស់ដល់យើង ដើម្បីនឹងព្យាបាលព្រះអាការរោគឲ្យបានយូរថ្ងៃសោះ គួរឲ្យយើងខ្ញុំស្ដាយក្រៃពេកណាស់នឹងរកពាក្យណាមួយថ្លែងរៀបរាប់ ពុំបានឡើយ។ ព្រះអង្គសោយទិវង្គតនេះ ធ្វើឲ្យរញ្ជួយសកលកម្ពុជា ព្រោះព្រះអង្គមានព្រះគុណធម៌ច្រើនណាស់លើពុទ្ធបរិស័ទ ទាំងបព្វជិត ទាំងគ្រហស្ថ។ សម្ដេចទ្រង់សោយព្រះទិវង្គត បាត់ព្រះរូបពិតមែន ប៉ុន្តែព្រះកិត្តិនាមឋិតនៅដដែល។

អស់លោកអ្នកពុទ្ធបរិស័ទទាំងឡាយ! ព្រះបរមសពនៃសម្ដេចព្រះសង្ឃរាជនេះ ជាព្រះសពត្រូវតម្កល់ទុកតាមផ្លូវការរបស់រាជរដ្ឋាភិបាល ដើម្បីធ្វើទក្ខិណានុប្បទានរៀងរាល់ថ្ងៃតទៅ ទម្រាំគណៈកម្មការបុណ្យជំនុំគ្នាដោះស្រាយ រៀបចំព្រះរាជពិធីបុណ្យព្រះបរមសពកំណត់យកថ្ងៃណា ខែណា តទៅជាក្រោយ។ ឥឡូវនេះ គណៈកម្មការបុណ្យបណ្ដោះអសន្ន បានព្រមព្រៀងយកថ្ងៃ១រោច ខែកទ្រ្ទបទ ត្រូវនឹងថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៦៩ ជាកិច្ចធ្វើទក្ខិណានុប្បទាន មានទេសនា និងវេរភត្ត រៀងរាល់យប់ថ្ងៃតរៀងទៅ ចំនួន៦ខែ គិតពីខែនេះទៅ ក្រោមព្រះរាជធិបតីភាពនៃសម្ដេចព្រះមហាក្សត្រីយានី និងសម្ដេចព្រះប្រមុខរដ្ឋ៕